ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៥៦២៥ សហវ-ប្រក

# ប្រកាស
## ស្តីពី
## ការពន្យារសុពលភាពអនុវត្តការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ របស់សហគ្រាសកាត់ដេរ និងសហគ្រាសផលិតស្បែកជើង

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៣០៥ សហវ.ប្រក.ពជ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០០៨ ស្តីពីការព្យួរទុកការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញរបស់សហគ្រាសកាត់ដេរ និងសហគ្រាសផលិតស្បែកជើង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៨៣ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីការពន្យារសុពលភាពការព្យួរទុក ការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញរបស់សហគ្រាសកាត់ដេរ និងសហគ្រាសផលិតស្បែកជើង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញប្រកាសលេខ ៩៨៨ សហវ.ប្រក ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០១១ ស្តីពីការពន្យារសុពលភាពការព្យួរទុក ការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញរបស់សហគ្រាសកាត់ដេរ និងសហគ្រាសផលិតស្បែកជើង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងចំណារសម្រេចដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១៥ លើលិខិតលេខ ៣៧៦៩ សហវ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១:** ការព្យួរទុកជាបណ្តោះអាសន្ន នូវការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញប្រចាំខែរបស់សហគ្រាសកាត់ដេរ និងសហគ្រាសផលិតស្បែកជើង ដែលបានអនុញ្ញាតដោយប្រកាសលេខ ៩៨៨ សហវ.ប្រក ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការពន្យារសុពលភាពការព្យួរទុក ការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញរបស់សហគ្រាសកាត់ដេរ និងសហគ្រាសផលិតស្បែកជើង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានពន្យារសុពលភាពអនុវត្តសម្រាប់រយៈ ០២ (ពីរ) ឆ្នាំបន្ថែមទៀត រហូតដល់ដំណាច់ឆ្នាំ២០១៧ ប៉ុន្តែសហគ្រាសត្រូវផ្សារភ្ជាប់ជាមួយការបង្កើនអនុលោមភាពតាមច្បាប់របស់អ្នកជាប់ពន្ធ ដែលក្នុងនោះមានលក្ខខណ្ឌដូចខាងក្រោម÷

១). សហគ្រាសត្រូវកាន់បញ្ជិកាគណនេយ្យ និងប្រកាសបង់ពន្ធប្រាក់ចំណេញ និងបំពេញកាតព្វកិច្ចពន្ធដារផ្សេងទៀតឲ្យបានត្រឹមត្រូវ

២). សហគ្រាសត្រូវផ្តល់របាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំជូនរដ្ឋបាលសារពើពន្ធ។

ក្នុងករណីសហគ្រាសមិនគោរពតាមលក្ខខណ្ឌទាំង២ខាងលើ អគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិដកហូតការព្យួរទុកបណ្តោះអាសន្ននេះវិញ ហើយសហគ្រាសត្រូវរងនូវទោសទណ្ឌផ្សេងៗតាមច្បាប់ជាធរមាន។

ដោយឡែកចំពោះសហគ្រាសដែលជាឧស្សាហកម្មគាំទ្រ សម្រាប់បម្រើឲ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតកាបូបយួរនិងកាបូបដៃ និងឧស្សាហកម្មផលិតមួក ដែលត្រូវជាប់អាករលើតម្លៃបន្ថែមតាមអត្រាសូន្យ ស្របតាមប្រកាសលេខ ៣១១ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវមានកាតព្វកិច្ចបង់ពន្ធអាករផ្សេងៗតាមច្បាប់ជាធរមាន។

**ប្រការ ២:** នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ២០១៥

**អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលារាជធានី-ខេត្ត
- ដូចប្រការ២
- រាជកិច្ច "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ